ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា
លេខ : ៩៥៨៥ ន.ទ.ក.

# សេចក្ដីជូនដំណឹង
# ស្ដីពី
# ការប្រតិបត្តិធុរកិច្ចនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) សូមជម្រាបជូនសាធារណជន និងបណ្ដាក្រុមហ៊ុនដែលបាន និងកំពុងប្រតិបត្តិធុរកិច្ចនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ថា ន.ទ.ក. ទទួលបានសំណើសុំអន្តរាគមន៍ពីក្រុមហ៊ុនភ្នាក់ងារ ដែលមានវិញ្ញាបនបត្រទទួលស្គាល់ដោយ ន.ទ.ក. និងទទួលបានសិទ្ធិស្របច្បាប់ពីក្រុមហ៊ុនផលិតគ្រឿងសម្ភារបរិក្ខារផ្ទាល់(Vendors) ក្នុងការនាំចូល ផ្គត់ផ្គង់ និងចែកចាយទូរស័ព្ទចល័តរបស់ក្រុមហ៊ុន Apple (iPhone) និងក្រុមហ៊ុន Samsung នាឡិកាឆ្លាតរបស់ក្រុមហ៊ុន Garmin និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ប្រភេទផ្សេងៗទៀត ដើម្បីជួយទប់ស្កាត់ការនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទាំងនោះ ដោយបុគ្គលខុសច្បាប់ ដែលពុំមានវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារ និង/ឬពុំមានចុះបញ្ជីទទួលស្គាល់យថាប្រភេទ (TA) នៅ ន.ទ.ក. ពីព្រោះថាការណ៍នេះបាននិងកំពុងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុនស្របច្បាប់។

ក្នុងន័យនេះ ដើម្បីលើកកម្ពស់ការប្រកួតប្រជែងដោយស្មោះត្រង់ និងការពារអ្នកប្រើប្រាស់ ន.ទ.ក. សូមជូនដំណឹងដល់សាធារណជន និងបណ្ដាក្រុមហ៊ុន ដូចបានរៀបរាប់ខាងលើ ត្រូវបញ្ឈប់÷

១. ការនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ ដោយគ្មានវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារពី ន.ទ.ក.

២. ការនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ ដែលគ្មានវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ (TA) និងលិខិតអនុញ្ញាតនាំចូល ពី ន.ទ.ក. និង

៣. ការនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ណាខុសពីទីផ្សារគោលដៅកំណត់ដោយក្រុមហ៊ុនផលិតគ្រឿងសម្ភារបរិក្ខារផ្ទាល់ (Vendors)។

ន.ទ.ក. សូមរំលេចជូននូវបញ្ញត្តិជាធរមានមួយចំនួននៃច្បាប់ស្ដីពីទូរគមនាគមន៍ ដូចខាងក្រោម÷

- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ទៅ ១ ខែ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៥ លានរៀល ចំពោះប្រតិបត្តិការធុរកិច្ចនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខាទូរគមនាគមន៍ ដោយគ្មានលិខិតអនុញ្ញាតនិងវិញ្ញាបនបត្រពី ន.ទ.ក. (មាត្រា ៨៩) K. PSR

- ចំពោះនីតិបុគ្គល ត្រូវពិន័យជាប្រាក់ពី ១០ លានរៀល ទៅ ៥០ លានរៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ (មាត្រា ៩០)
- រឹបអូសគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ខុសច្បាប់ និង
- ពិន័យផ្សេងៗទៀត។

ជាមួយគ្នានេះ ន.ទ.ក. សូមរំលឹកជូនផងដែរថា ក្នុងករណី ន.ទ.ក. រកឃើញថា សាធារណជន និងក្រុមហ៊ុន នៅតែបន្តធ្វើសកម្មភាពផ្ទុយនឹងច្បាប់ដូចខាងលើ នោះ ន.ទ.ក. នឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ទន្ទឹមនឹងនេះ ន.ទ.ក. សូមអំពាវនាវដល់សាធារណជន និងក្រុមហ៊ុនចូលរួមសហការ និងរាយការណ៍អំពីសកម្មភាពខុសច្បាប់ដូចបានរៀបរាប់ខាងលើ មក ន.ទ.ក. តាមរយៈទូរស័ព្ទលេខ ៦៧៨៩ រៀងរាល់ម៉ោងធ្វើការ ឬ ផ្ញើសារមកកាន់អ៊ីម៉ែល info@trc.gov.kh។

អាស្រ័យហេតុនេះ សូមសាធារណជន និងក្រុមហ៊ុនប្រតិបត្តិការធុរកិច្ចនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ទាំងអស់ជ្រាបនិងចូលរួមសហការ។ K. 88 PSR

ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣